**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ១៩៩៩
ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩
សាលក្រមលេខ៖ ០៩ "ន"
ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ដោយមានសមាសភាពចូលរួមដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**<u>ដើម្បីជំនុំជម្រះ</u>**

សំណុំរឿងព្រហ្មទណ្ឌលេខ ១៩៩៩ ចុះថ្ងៃទី ២៥/០៨/២០០៩ ដែលមានជនជាប់ចោទ

ឈ្មោះ [redacted] **ណារិន** ភេទប្រុស អាយុ ៨៨ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើត ភូមិកញ្ចាំ ឃុំកញ្ចាំ ស្រុកពារាំង ខេត្តព្រៃវែង សាសនា ព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ៣៦E, សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] ប្រពន្ធ ឈ្មោះ [redacted] មានកូន ០២ នាក់ ទោសពីមុន គ្មាន ជាទីតិជន ។

ដោយមានលោក [redacted] ទី ជាមេធាវីការពារឲ្យជនជាប់ចោទ ។

ជាប់ចោទពីបទ៖ **បង្ករបួសដោយចេតនា ដេរប្រមាថ និងបរិហារកេរ្តិ៍** ប្រព្រឹត្តនៅផ្សារសំពៅមាស សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០/០៨/២០០៩ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

<u>អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ</u> ៖

-កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ០៥:៣០នាទីល្ងាច ពេលប្តីឈ្មោះ [redacted] ផល្លា បើកឡានចេញពីក្នុងផ្សារសំពៅមាស ពីកន្លែងលក់ដូរខាងក្នុង មកតាមច្រកផ្លូវចំហៀងតូបរបស់ឈ្មោះ [redacted] **ណារិន** លុះពេលបើកមកដល់ត្រង់ចំនុចចំហៀងតូប ស្រាប់តែឈ្មោះ [redacted] **ណារិន** បានទំលាក់ទ្វារតូបមកប៉ះឡានរបស់ [redacted] ផល្លា តែពេលនោះដោយឈ្មោះ [redacted] ផល្លា មានធុរៈត្រូវជូនកូនទៅសាលារៀន

ផង កំមិនបានចុះទៅសួរនាំអ្វីដែរ ។ លុះព្រឹកថ្ងៃទី ២០/០៨/២០០៩ វេលាម៉ោង ៧:០០ នាទី ពេលប្តីបើកឡានមកដល់ត្រង់ចំនុចចំហៀងតូបរបស់[redacted] ណារិន ឈ្មោះ[redacted]ល្លា ក៏ដើរទៅសួរនាំពីរឿងដែល [redacted] ណារិន ធ្វើឲ្យប៉ះឡាន ពេលនោះស្រាប់តែឈ្មោះ [redacted]ណារិន បានជេរប្រមាថ និងចាប់មួលដៃឈ្មោះ [redacted]ផល្លា បណ្តាលឲ្យគ្រេចជ្លោះដៃយ៉ាងធ្ងន់ធ្ងរ ភ្លាមនោះប្តី [redacted] ផល្លា ឃើញហេតុការណ៍ដូចនោះ កំចេញពីក្នុងឡានទៅចាប់ប្រពន្ធចេញតែម្តង ។

-បានឃើញ ពាក្យបណ្តឹងចុះថ្ងៃទី ២១/០៨/២០០៩ របស់ឈ្មោះ[redacted]ផល្លា ភេទស្រី អាយុ ៣៩ឆ្នាំ ។

-បានឃើញ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៩៣១៧តព្រ ចុះថ្ងៃទី ៣០/០៣/២០១០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ១០៩៣ អ.យ.ឆ ចុះថ្ងៃទី ២២/០៦/២០១០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ១២៨៧ ដជរ ចុះថ្ងៃទី ២៩/០៦/២០១០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

<u>នាពេលសវនាការៈ</u>

-ជនជាប់ចោទឈ្មោះ[redacted]ណារិន បានឆ្លើយថា៖ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនមានសាក្សីចំនួន ៣នាក់ មកឆ្លើយបញ្ជាក់កាលពីថ្ងៃទី ១៨/០៨/២០០៩ ឈ្មោះ[redacted] លី ដែលត្រូវជាប្តីរបស់ឈ្មោះ ផល្លា ស្រវឹងស្រា ហើយបានបើកឡានចូលក្នុងផ្សារ ហើយចង់កិនរបស់របរលក់ដូររបស់ខ្លួនទៀត នឹងបានជេរប្រមាថខ្លួនថា អាឆ្កែ អាមោក ហើយគេថាបើកបំបុកតូបខ្លួនឲ្យខ្ទេច ។

នៅថ្ងៃទី ២០/០៨/២០០៩ ឈ្មោះ ផល្លា និងប្តី បានបើកឡានមកបុកតូបខ្លួន ហើយសួរខ្លួនថា ពូរឿងដាក់ទ្វារតូបបុកឡានគាត់ ហើយខ្លួនក៏និយាយថាមិនដែលតូបទៅប៉ះឡានទេ ហើយគាត់បានទារលុយពីខ្លួន ១០$ ថ្លៃជួសជុលឡានរបស់គាត់ ខ្លួនថាអត់មានលុយទេ ពេលនោះឈ្មោះ ផល្លា បាននិយាយថាប្តីគាត់កាចណាស់ ស្រាប់តែប្តីគាត់ចុះមកមែន ហើយនិយាយថាអ្ហែងលុយ ១០$ ក៏គ្មានដែរ ព្រមទាំងជេរខ្លួនថាអាឆ្កែ អាចុយម្រាយ ពេលនោះខ្លួនងើបមុខឡើង ស្រាប់តែប្តីរបស់ឈ្មោះ ផល្លា ដាល់ ខ្លួនពីរបីដៃធ្វើអោយខ្លួនវង្វេងស្មារតីហើយពេលនោះឈ្មោះ សាព៉ក់ បានហៅម៉ូតូឌុបខ្លួនទៅមន្ទីរពេទ្យ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ផល្លា ឆ្លើយថា៖ កាលពីថ្ងៃទី ១៩/០៨/២០០៩ វេលាម៉ោង ៥ ៣០នាទី ពេលនោះខ្លួនពីរនាក់ប្តីប្រពន្ធ បានបើករថយន្តចេញតាមផ្លូវ ចេញតាមតូបគាត់ ហើយប៉ះឡានបណ្តាល<u>ឲ្យឆ្កូតដាច់</u>សាច់ថ្នាំឡានរបស់ខ្លួន តែពេលទៅដល់ផ្ទះទើបដឹង លុះពេលព្រឹកឡើងថ្ងៃទី ២០/០៨/២០០៩ ខ្លួនក៏ទៅសួរឈ្មោះ [redacted]ណារិន ពីរឿងខូចឡានដើម្បីឲ្យគាត់ជួយចេញថ្លៃធ្វើឡានចំនួន ១០$ ពេលនោះឈ្មោះ[redacted]ណារិន បានចាប់ផ្តើមជេរប្រមាថខ្លួនថា "ឯង ចោក" បើអស់ពីរយដុល្លារអ័អញឲ្យបើអស់ ១០$ អីមកទារធ្វើអី ឯងមានឡានជិះហើយ ទៅបាញ់ថ្នាំខ្លួនឯងទៅ ពេលនោះខ្លួនចង្អុលឈ្មោះ[redacted]ណារិន ស្រាប់តែឈ្មោះ [redacted]ណារិន ចាប់ដៃខ្លួនមួល បណ្តាលឲ្យជ្លោះគ្រេច ហើយខ្លួនព្យាបាលអស់រយៈពេល ២ខែ អស់ប្រាក់ ៣០០$ ទើបជាសះស្បើយ ចំណែកប្តីខ្លួនមិនបានវាយឈ្មោះ [redacted]ណារិន ទេ ខ្លួនសុំទាមទារថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្ត ២៥០០$ ។

-សាក្សីឈ្មោះ [redacted]សាព៉ត ឆ្លើយថា៖ ខ្លួនអាយុ ១៩ឆ្នាំ ខ្លួនបានរៀបការហើយ នៅថ្ងៃកើតហេតុខ្លួនបានឃើញឈ្មោះ[redacted] ផល្លា និងប្តីចុះពីលើរថយន្តមកសុំលុយពីឈ្មោះ[redacted] ណារិន ថ្លៃជួសជុលរថយន្ត ។ ខ្លួនពុំបានឃើញឈ្មោះ[redacted]ណារិន ប្រតាយប្រតប់គ្នាជាមួយឈ្មោះ[redacted]ផល្លា ទេ ។



Scanned by CamScanner

38/4

-សាក្សីឈ្មោះ [redacted] សារិន បានឆ្លើយថា៖ ខ្លួនអាយុ ២៣ឆ្នាំ ខ្លួនបានស្បថរួចហើយ ។ នៅថ្ងៃកើតហេតុ ខ្លួនឃើញឈ្មោះ លី និងឈ្មោះ ផល្លា ចុះពីរថយន្តមកនិយាយជាមួយឈ្មោះ ណារិន ហើយខ្លួនបានឃើញឈ្មោះ ណារិន ប្រតាយប្រតប់គ្នាជាមួយឈ្មោះ លី ដែលត្រូវជាប្ដីរបស់ឈ្មោះ ផល្លា ចំនែកឈ្មោះ ផល្លា ពុំឃើញប្រតាយប្រតប់គ្នាជាមួយឈ្មោះ ណារិន ទេ ។

-សាក្សីឈ្មោះ [redacted] បញ្ញា បានឆ្លើយថា៖ ខ្លួនអាយុ ២០ឆ្នាំ ខ្លួនជួលតូបលក់កែបម៉ូតូ ។ នៅថ្ងៃទី ២០/០៨/២០០៩ ខ្លួនបានឃើញឈ្មោះ លី សុំលុយពីឈ្មោះ ណារិន ដើម្បីយកទៅបាញ់ថ្នាំឡាន បន្ទាប់មកខ្លួនក៏ឃើញក៏រួចកអាវវាយគ្នាតែម្ដង ។

-សាក្សីឈ្មោះ [redacted] មឿន បានឆ្លើយថា៖ នៅថ្ងៃទី ២០/០៨/២០០៩ ខ្លួនឃើញឈ្មោះ លី និងប្រពន្ធបើកឡានមកដល់ ចុះមកទារលុយ ១០$ ពីឈ្មោះ ណារិន យកទៅទិញថ្នាំ ហើយឈ្មោះ ណារិន ថាគ្មានលុយឲ្យទេ បើអស់ ១០០$ ឬ ២០០$ ទើបឲ្យ ហើយក៏មានការប្រតាយប្រតប់គ្នា ខ្លួនក៏ទៅឃាត់តែម្ដង ។

-សាក្សីឈ្មោះ [redacted] ហ៊ឹម បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនឃើញស្រីម្នាក់ ចុះពីលើឡាន ដើរទៅកេឈ្មោះ [redacted] ណារិន មិនដឹងនិយាយរឿងអ្វីទេ ខ្លួននៅចំងាយប្រហែល ១០ម៉ែត្រជាង ខ្លួនឃើញប្រកែកគ្នា ហើយក៏ប្រតាយប្រតប់គ្នា ខ្លួនក៏ចូលទៅឃាត់ទាំងសងខាង ពេលនោះខ្លួនឃើញប្ដីចុះពីលើរថយន្តទៅ ខ្លួនក៏ទៅឃាត់ប្ដីទៀត ខ្លួនពុំឃើញជនរងគ្រោះមានរបួសទេ តែលឺជនរងគ្រោះថាឈឺដៃ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ តាងនាមខ្លួនតំណាងអយ្យការ នៅតែក្សាដីកាសន្និដ្ឋានស្ថាពរលេខ ១០៩៣ អ.យ.ធ ចុះថ្ងៃទី ២២/០៦/២០១០ នៅដដែល ។ យោងមាត្រា១០ ស្ដីកែប្រែពីមាត្រា ៦៣ថ្មី និងមាត្រា ៨១ មកមាត្រា ៣០៥ និង មាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌវិញ ។

-មេធាវីការពារជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ នៅថ្ងៃកើតហេតុគឺម៉ោង ៨ ឯសាក្សីឈ្មោះ មឿន ថាម៉ោង ៧ជាង និងខុសគ្នាត្រង់ចំងាយមួយថា ៥ម៉ែត្រ មួយទៀតថា ១០ម៉ែត្រ ផ្ទុយគ្នា និងពេលវេលា ហើយនៅក្នុងផ្សារគ្មានច្បាប់អនុញ្ញាតិឲ្យបើកបរក្នុងផ្សារទេ ។ តាមលិខិតបញ្ជាក់ថាអស់ ៣០០$ និង ១៥០.០០០(ដប់ប្រាំម៉ឺនរៀល) មន្ទីរពេទ្យមិនមែនពេទ្យបង្អែកទេ ។ ឆ្លងតាមអង្គហេតុ កូនក្ដីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដូច្នេះសូមឲ្យតុលាការលើកលែងចោទប្រកាន់ដល់កូនក្ដីខ្លួន ។

-ជនជាប់ចោទនិយាយសម្ដីចុងក្រោយថា៖ សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned by CamScanner

## សាលាដំបូងរាជធានីភ្នំពេញ

### យល់ឃើញថា ៖

-តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ១២៨៧ ដជរ ចុះថ្ងៃទី ២៩/០៦/២០១០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការចោទប្រកាន់ទៅលើឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ ៨៨ឆ្នាំ ជាតិខ្មែរ ពីបទ: **បង្ករបួសដោយចេតនា ជេរប្រមាថ និង បរិហាកេរ្តិ៍** ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០/០៨/២០០៩ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ណារិន បានឆ្លើយថា: កាលពីថ្ងៃទី ២០/០៨/២០០៩ ឈ្មោះ [redacted] ផល្លា និងប្តីបានបើកឡានមកបុកតូបខ្លួន ហើយចោទថាខ្លួនដាក់ទ្វារតូបឬកឡានគាត់ ពេលនោះខ្លួនក៏និយាយថាមិនដែលតូបទៅប៉ះឡានទេ ហើយគាត់បានទារលុយពីខ្លួន ១០$ ដើម្បីជួសជុលឡានរបស់គាត់ ខ្លួនថាអត់មានលុយទេ ពេលនោះស្រាប់តែប្តីរបស់ឈ្មោះ [redacted] ផល្លា ចុះពីលើឡានមក ជេរខ្លួនថាអាឆ្កែ អាចុយម្រាយ ពេលនោះខ្លួនងើបមុខឡើង ស្រាប់តែគាត់ដាល់ខ្លួនពីរបីដៃធ្វើឲ្យខ្លួនវង្វេង ស្មារតី ហើយឈ្មោះ សាព៉ក់ បានហៅម៉ូតូឌុបខ្លួនទៅមន្ទីរពេទ្យតែម្តង ដោយខ្លួនមិនបានវាយតបទៅលើឈ្មោះ ផល្លា និងប្តីទេ ។

-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល្លា បានឆ្លើយថា: កាលពីថ្ងៃទី ១៩/០៨/២០០៩ វេលាម៉ោង ០៥:៣០នាទី ខ្លួនពីរនាក់ប្តីប្រពន្ធបានបើករថយន្តចេញតាមផ្លូវតូបរបស់ឈ្មោះ [redacted] ណារិន ហើយក៏ប៉ះឡានបណ្តាលឲ្យឆ្កូតដាច់សាច់ថ្នាំឡានរបស់ខ្លួន ។ លុះពេលព្រឹកឡើងថ្ងៃទី ២០/០៨/២០០៩ ខ្លួនបានទៅសួរឈ្មោះ [redacted] ណារិន ពីរឿងខូចឡាន ដើម្បីឲ្យគាត់ជួយចេញថ្លៃធ្វើឡានចំនួន ១០$ ពេលនោះស្រាប់តែឈ្មោះ [redacted] ណារិន ជេរប្រមាថថាខ្លួន "ថោក" អស់១០$ ក៏ទារពីគាត់ដែរ ហើយខ្លួនក៏ចង្អុលមុខ [redacted] ណារិន ស្រាប់តែឈ្មោះ [redacted] ណារិន ចាប់ដៃខ្លួនមួល បណ្តាលឲ្យផ្លោះគ្រិចតែម្តង ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] សាព៉ត និង ឈ្មោះ [redacted] សារិន បានឆ្លើយប្រហាក់ប្រហែលគ្នាថា នៅថ្ងៃទី ២០/០៨/២០០៩ ពួកខ្លួនបានឃើញឈ្មោះ លី និងប្រពន្ធឈ្មោះ [redacted] ផល្លា បានចុះពីរថយន្តមកនិយាយជាមួយឈ្មោះ [redacted] ណារិន ដើម្បីទារលុយថ្លៃជួសជុលរថយន្ត បន្ទាប់មកពួកខ្លួនបានឃើញឈ្មោះ លី និងឈ្មោះ [redacted] ណារិន ប្រតាយប្រតប់គ្នា ចំណែកឈ្មោះ [redacted] ផល្លា មិនបានប្រតាយប្រតប់គ្នាជាមួយឈ្មោះ [redacted] ណារិនទេ ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] មឿន និងឈ្មោះ [redacted] ហ៊ីម បានឆ្លើយប្រហាក់ប្រហែលគ្នាថា នៅថ្ងៃទី ២០/០៨/២០០៩ ពួកខ្លួនឃើញឈ្មោះ លី និងប្រពន្ធឈ្មោះ [redacted] ផល្លា បើកឡានមកទារលុយពីឈ្មោះ [redacted] ណារិន ចំនួន ១០$ ថ្លៃជួសជុលរថយន្ត ដោយឈ្មោះ [redacted] ផល្លា ជាអ្នកទៅទារ នៅពេលទៅទារលុយពីឈ្មោះ [redacted] ណារិន ឈ្មោះ [redacted] ណារិន ថាគ្មានលុយទេ ហើយក៏មានការប្រតាយប្រតប់ ពួកខ្លួនក៏ចូលទៅឃាត់ ក្រោយមកឈ្មោះ លី ក៏ចុះពីលើរថយន្តមក ពួកខ្លួនក៏ជួយឃាត់ទៀត ពេលហេតុការណ៍ចប់ពួកខ្លួនមិនបានឃើញឈ្មោះ [redacted] ផល្លា មានរបួសអីទេ តែលីថាឈឺដៃ ។



Scanned by CamScanner

-តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងចម្លើយសាក្សី មានលក្ខណៈស៊ីសង្វាក់ គ្នាទៅនឹងភស្តុតាងឯកសារផ្សេងទៀត អាចឲ្យតុលាការកំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ ៤៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់របស់អយ្យការ ប្រាកដមែន ។

-ការឆ្លើយដោះសាររបស់ ជនជាប់ចោទថាមិនបានប្រតាយប្រតប់គ្នា និងមិនបានវាយទៅលើជនរងគ្រោះទេនោះ គ្មានភស្តុតាងតាមផ្លូវច្បាប់ ដើម្បីយកមកធ្វើជាមូលដ្ឋានសំអាងក្នុងការដោះបន្ទុកឲ្យរួចខ្លួនពីការចោទប្រកាន់បានទេ ។

-អំពើរបស់ជនជាប់ចោទ បានបំពានទៅលើ បូរណភាពរាងកាយ កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់រូបវន្តបុគ្គល ប៉ះពាល់ដល់ សណ្ដាប់ធ្នាប់សាធារណៈ ដែលច្បាប់បានហាមឃាត់ និងបានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទជានីតិជន មានស្មារតីគ្រប់គ្រាន់ដឹងខុសត្រូវ នៅពេលដែលប្រព្រឹត្តបទល្មើសដែលខ្លួនបានប្រព្រឹត្ត ហេតុនេះជនជាប់ចោទត្រូវតែទទួលខុសត្រូវនូវ ទង្វើរបស់ខ្លួនចំពោះមុខច្បាប់ ដែលខ្លួនបានប្រព្រឹត្ត ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ ៤៨ឆ្នាំ ពីបទ **បង្ករបួសដោយចេតនា និង ជេរប្រមាថ** ប្រព្រឹត្តនៅផ្សារសំពៅមាស រាជធានីភ្នំពេញ កាលពីថ្ងៃទី **២០/០៤/២០០៩** បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

-យោងតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌស្ដីពីការអនុវត្តច្បាប់ព្រហ្មទណ្ឌ ស្រាលជាង ឬធ្ងន់ជាង (ការអនុវត្តច្បាប់ដែលធ្ងន់ជាង រឺស្រាលជាង: បទបញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែការផ្ដន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។) ហេតុនេះ តុលាការគប្បីពិចារណា និងសម្រេចកែតម្រូវការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ ៤៨ឆ្នាំ ពីបទ **ជេរប្រមាថ និងបរិហាកេរ្តិ៍** តាមមាត្រា ៦៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ព្រហ្មទណ្ឌអន្តរកាល មកបទជេរប្រមាថជាសាធារណៈ តាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល្លា បានទាមទារសំណងថ្លៃថ្នាំព្យាបាលជំងឺចិត្តចំនួន ២.៥០០$ (ពីរពាន់ប្រាំរយដុល្លារអាមេរិច) គប្បីតុលាការពិចារណាតាមភាពជាក់ស្ដែង ។

-តំណាងអយ្យការបានសន្និដ្ឋានប្ដឹងសុំថា សុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល និងសុំឲ្យតុលាការផ្ដន្ទាទោស ជនជាប់ចោទតាមច្បាប់ ។



Scanned by CamScanner

៤០

38/1

## សាលាដំបូងរាជធានីភ្នំពេញ
## វិនិច្ឆ័យសេចក្ដី

១. កែតម្រូវបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted]ណារិន ពីបទ ជេរប្រមាថ និង បរិហារកេរ្តិ៍ ប្រព្រឹត្តនៅផ្សារសំពៅមាស សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០/៨/២០០៩ តាមមាត្រា៦៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម មាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មក **បទជេរប្រមាថ** ជាសាធារណៈ តាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

២. ផ្ដន្ទាទោសឈ្មោះ [redacted] **ណារិន** ភេទប្រុស អាយុ ៨៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ) ខែ តែទោសនេះត្រូវព្យួរចម្ងាត និងពិន័យជាប្រាក់ចំនួន ១,០០០,០០០ (មួយលាន)រៀល ។

ពីបទ **បង្ករបួសដោយចេតនា** និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅផ្សារសំពៅមាស សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០/៨/២០០៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៣០៧ និង មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

៣. បង្គាប់ឲ្យឈ្មោះ [redacted] ណារិន សងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តចំនួន ៨,០០០,០០០(ប្រាំបួនលាន) រៀល ឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ជល្លា ការទាមទារលើសពីនេះបដិសេធចោល ។

៤. សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។

បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

**បានឃើញ**
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១
**ចៅក្រមជំនុំជម្រះ**

[redacted]

*បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។*
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១
**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner